

អង្គរ ជេនេរ៉ល អ៊ិនសួរេន ម.ក
ANGKOR GENERAL INSURANCE PLC.

បណ្ណសន្យាវ៉ាប់រង
ឆានាវ៉ាប់រងរូបិយវត្ថុ

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូត៍C, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់ភលរង់ ខណ្ឌ៧មកភ
ភជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

តារាងមាតិកា

ផ្នែកទី១៖ និយមន័យ 3
ផ្នែកទី ២៖ កម្មវត្ថុនៃការធានា 3
ផ្នែកទី ៣៖ ទិសាលភាពធានារ៉ាប់រង 4
ផ្នែកទី ៤៖ អត្ថប្រយោជន៍នៃការធានា 5
ផ្នែកទី ៥៖ ការបង់បុព្វលាភធានារ៉ាប់រង 5
ផ្នែកទី ៦៖ ករណីមិនធានា 6
ផ្នែកទី ៧៖ ទីតាំងភូមិសាស្ត្រនៃការធានា 9
ផ្នែកទី ៨៖ លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង 9
ផ្នែកទី ៩៖ ការកែប្រែកិច្ចសន្យាធានារ៉ាប់រង 9
ផ្នែកទី ១០៖ ការបន្តកិច្ចសន្យាធានារ៉ាប់រង 10
ផ្នែកទី ១១៖ ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង 10
ផ្នែកទី ១២៖ ការលុបចោលកិច្ចសន្យាធានារ៉ាប់រង 11
ផ្នែកទី ១៣៖ ការទាមទារសំណង 11
ផ្នែកទី ១៤៖ ការរក្សាព័ត៌មានសម្ងាត់ 14
ផ្នែកទី ១៥៖ នីតិវិធីនៃការផ្សះផ្សាវិវាទ 15
ផ្នែកទី ១៦៖ ច្បាប់ និងយុត្តាធិការ 15
ផ្នែកទី ១៧៖ លក្ខខណ្ឌទូទៅ 15
ផ្នែកទី ១៨៖ នីតិវិធីប្តឹងតវ៉ា 17
ផ្នែកទី ១៩៖ ព័ត៌មានទំនាក់ទំនង 18

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍C, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី១៖ និយមន័យ

- **ម៉ោងការងារ៖** សម្តៅដល់ម៉ោងបំពេញការងារទូទៅរបស់អ្នកត្រូវបានធានារ៉ាប់រង (ដោយរួមបញ្ចូលការងារថែមម៉ោង) នៅអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រង ឬបុគ្គលិករបស់ខ្លួនដែលត្រូវបានប្រគល់ឱ្យនូវរូបិយវត្ថុ គឺស្ថិតនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង ឬទីកន្លែងនៅក្នុងបណ្ណសន្យារ៉ាប់រង របស់អ្នកត្រូវបានធានារ៉ាប់រងសម្រាប់គោលបំណងអាជីវកម្មមានកំណត់ក្នុងបណ្ណសន្យារ៉ាប់រង។
- **រូបិយវត្ថុ៖** សម្តៅដល់សាច់ប្រាក់ ក្រដាសប្រាក់ រូបិយបណ្ណក្នុងស្រុក ឬរូបិយបណ្ណបរទេស មូលប្បទានបត្រ ទោះបីជាចេញជូនអោយបុគ្គលណាមួយដោយមិនបានកំណត់ចំនួនទឹកប្រាក់ ឬដោយទឹកប្រាក់ជាក់លាក់ បណ្ណប្រៃសណីយ៍ បណ្ណទូទាត់ តែមប្រាក់ចំណូល ឬតែមលើថ្លៃបញ្ជូនសំបុត្រ ដែលជាកម្មសិទ្ធិរបស់អ្នកត្រូវបានធានារ៉ាប់រង ឬដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវមានទំនួលខុសត្រូវ។
- **ម្ចាស់បណ្ណសន្យារ៉ាប់រង៖** សម្តៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង។
- **វិញ្ញាបនបត្រធានារ៉ាប់រង៖** សម្តៅដល់ឯកសារដែលចេញដោយក្រុមហ៊ុន លើសេចក្តីសង្ខេបពីខសន្យាលក្ខខណ្ឌនានា ករណីមិនធានា និងបុព្វលាភធានារ៉ាប់រង ដែលត្រូវបានកំណត់ថ្លៃ និងផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រង។
- **រយៈពេលនៃការធានារ៉ាប់រង៖** សម្តៅដល់រយៈពេលដែលមានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និង រយៈពេលបន្តបន្ទាប់ដែលអ្នកដែលត្រូវបានធានាត្រូវបង់បុព្វលាភ ហើយក្រុមហ៊ុនយើងខ្ញុំបានទទួលនូវបុព្វលាភបន្តធានារ៉ាប់រង។
- **អ្នកត្រូវបានធានារ៉ាប់រង៖** សម្តៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រង និងអាចជាអ្នកត្រូវបានធានារ៉ាប់រងផងដែរ។
- **អ្នក/ខ្លួនអ្នក/របស់អ្នក៖** សម្តៅដល់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងដែលបានកំណត់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
- **ក្រុមហ៊ុន៖** សម្តៅដល់ក្រុមហ៊ុន **អង្គរ ជេនេរ៉ល អ៊ិនសួរេន ម.ក**។

ផ្នែកទី ២៖ កម្មវត្ថុនៃការធានា

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

បណ្ណសន្យារ៉ាប់រងនេះធានាលើការបាត់បង់របស់អ្នកត្រូវបានធានារ៉ាប់រងលើសាច់ប្រាក់ កាក់ តែមប្រៃសណីយ៍ និងមូលប្បទានប័ត្រ ខណៈពេលកំពុងដឹកជញ្ជូន (ដោយបុគ្គលដែលមានការអនុញ្ញាត) ឬក្នុងទូសុវត្ថិភាពចាក់សោនៅទីតាំងភូមិសាស្ត្រដែលត្រូវបានធានាដោយអនុលោមតាមលក្ខខណ្ឌ និងករណីមិនធានានៃកិច្ចសន្យាធានារ៉ាប់រងនេះ។

ផ្នែកទី ៣: វិសាលភាពធានារ៉ាប់រង

ក្រុមហ៊ុននឹងធ្វើសំណងជូនអ្នកត្រូវបានធានារ៉ាប់រងលើការបាត់បង់រូបិយវត្ថុ ឬខូចខាតណាមួយរហូតដល់ចំនួនដែលត្រូវបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង ដែលកើតមានឡើងនៅក្នុងរយៈពេលធានារ៉ាប់រង ដោយយោងទៅតាមខ លក្ខខណ្ឌ និងករណីមិនធានាដែលមានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះ។

ក. ការបាត់បង់រូបិយវត្ថុក្នុងពេលដឹកជញ្ជូន

រូបិយវត្ថុស្ថិតក្នុងការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ អ្នកដែលត្រូវបានប្រគល់សិទ្ធិក្នុងអំឡុងពេលដឹកជញ្ជូន ពីបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងទៅដល់ធនាគារ ឬពីធនាគារមកកាន់បរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងពេលធ្វើប្រតិបត្តិការអាជីវកម្មធម្មតា។

ខ. ការបាត់បង់រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង

ការបាត់បង់រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងរយៈពេលគ្មានប្រតិបត្តិការការងារត្រូវកំណត់លក្ខខណ្ឌថារូបិយវត្ថុនោះត្រូវទុកក្នុងទូសុវត្ថិភាពចាក់សោ ឬដាក់ក្នុងឃ្លាំងសុវត្ថិភាពត្រឹមត្រូវនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង។

១. ការបាត់បង់រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងម៉ោងការងារ

រូបិយវត្ថុដែលបានបាត់បង់នៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងម៉ោងការងារធម្មតា។

២. ការបាត់បង់រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្រៅម៉ោងការងារ

រូបិយវត្ថុដែលបានបាត់បង់នៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្រៅម៉ោងការងារ។

៣. ការបាត់បង់រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងទូសុវត្ថិភាព ឬឃ្លាំងសុវត្ថិភាព

រូបិយវត្ថុដែលបានបាត់បង់នៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងកំណត់ចំពោះតែរូបិយវត្ថុដែលទុកក្នុងទូសុវត្ថិភាពចាក់សោ ឬដាក់ក្នុងឃ្លាំងសុវត្ថិភាពត្រឹមត្រូវតែប៉ុណ្ណោះ។

៤. ការបាត់បង់រូបិយវត្ថុនៅក្នុងម៉ាស៊ីនអេធីអឹម (ATM)

ការបាត់បង់រូបិយវត្ថុដែលបានដាក់ក្នុងម៉ាស៊ីនអេធីអឹម (ATM) នៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង និងក្រៅបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង។

៥. ការបាត់បង់ ឬការខូចខាតទូសុវត្ថិភាព ឬឃ្លាំងសុវត្ថិភាព

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ការបាត់បង់ ឬការខូចខាតទូរសុវត្ថិភាព ឬឃ្លាំងសុវត្ថិភាពដែលបណ្តាលមកពីការចូលគាស់លួចយករូបិយវត្ថុ ឬការគម្រាមកំហែងដោយចេតនាណាមួយ។

ផ្នែកទី ៤៖ អត្ថប្រយោជន៍នៃការធានា

កិច្ចសន្យាធានារ៉ាប់រងនេះ នឹងត្រូវបានផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រងនូវការធានាលើការបាត់បង់ក្នុងអំឡុងពេលដំណើរការអាជីវកម្មរបស់ពួកគេ ដែលតម្រូវឱ្យមានការធានាចំពោះការបាត់បង់ប្រាក់ ដោយសារតែការលួច ប្លន់ បង្ខាំង ឬការគម្រាមកំហែងដោយចេតនាណាមួយ ហើយអាចត្រូវបានធានាលើមូលដ្ឋានដូចខាងក្រោម៖

ក. ការបាត់បង់រូបិយវត្ថុក្នុងពេលដឹកជញ្ជូន

រូបិយវត្ថុក្នុងអំឡុងពេលដឹកជញ្ជូនពីបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងទៅធនាគារ និងការត្រលប់មកវិញ ឬចាប់ពីការទទួលបានរូបិយវត្ថុនៅគ្រប់ទីកន្លែង រហូតដល់ពេលបញ្ជូនទៅដល់ធនាគារណាមួយ ឬបរិវេណធានារ៉ាប់រង។ ការទទួលខុសត្រូវជាអតិបរមារបស់ក្រុមហ៊ុន គឺទៅតាមចំនួនកម្រិតរបស់ទឹកប្រាក់ធានារ៉ាប់រងដូចមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

ខ. ការបាត់បង់រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង

- រូបិយវត្ថុនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលរូបិយវត្ថុត្រូវបានទុកក្នុងទូចាក់សោទូសុវត្ថិភាព ឬឃ្លាំងសុវត្ថិភាព
- ការបាត់បង់រូបិយវត្ថុដែលបានដាក់ក្នុងម៉ាស៊ីនអេធីអឹមនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង និងក្រៅបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រង និងនៅក្នុងបរិវេណធានារ៉ាប់រងជាក់លាក់ផ្សេងទៀត

ការទទួលខុសត្រូវជាអតិបរមារបស់ក្រុមហ៊ុន គឺទៅតាមចំនួនកម្រិតរបស់ទឹកប្រាក់ធានារ៉ាប់រងដូចមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

បណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបានផ្តល់ជូនផងដែរនូវការធានា៖

- ថ្លៃចំណាយក្នុងការជួសជុល ឬកែលម្អសម្រាប់ទូសុវត្ថិភាព ឬឃ្លាំងសុវត្ថិភាពដែលត្រូវបានខូចខាតដោយសារការលួច ឬប៉ុនប៉ងគាស់ចូលលួចរបស់ចោរ ទោះបីជាកម្មវត្ថុទាំងនោះមិនបានបញ្ជាក់ក្នុងការធានារ៉ាប់រង។

ផ្នែកទី ៥៖ ការបង់បុព្វលាភធានារ៉ាប់រង

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ការបង់បុព្វលាភគឺត្រូវបង់ជាប្រចាំឆ្នាំ និងគណនាបុព្វលាភទៅតាមសមាមាត្រប្រសិនបើមានការបន្ថែម ឬលុបចោលណាមួយនៅក្នុងរយៈពេលធានារ៉ាប់រង។

នេះគឺជាលក្ខខណ្ឌពិសេសជាមូលដ្ឋាន និងតែមួយគត់នៃបណ្ណសន្យារ៉ាប់រងនេះ ដែលតម្រូវថាបុព្វលាភធានារ៉ាប់រងដែលដល់ពេលត្រូវបង់ គឺត្រូវតែបង់ និងទទួលបានដោយក្រុមហ៊ុនក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រងនេះ/បដិ្ឋលេខ/លិខិតបញ្ជាក់អំពីការបន្តបណ្ណសន្យារ៉ាប់រង។
ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានអនុវត្តតាមនោះទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបានចាត់ទុកជាមោយៈដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភធានារ៉ាប់រងតាមសមាមាត្រនៃរយៈពេលដែលខ្លួនស្ថិតនៅក្នុងហានិភ័យ។

អ្នកត្រូវបានធានារ៉ាប់រង អាចធ្វើការបង់បុព្វលាភធានារ៉ាប់រងមកកាន់ក្រុមហ៊ុនតាមរយៈ៖ ការបង់ជាសាច់ប្រាក់ ការបង់ជាមូលប្បទានប័ត្រ កម្មវិធីទូទាត់ផ្សេងៗរបស់ក្រុមហ៊ុន ឬក៏ផ្ទេរតាមរយៈគណនីធនាគារផ្ទាល់របស់ក្រុមហ៊ុន **អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក** ។

ផ្នែកទី ៦៖ ករណីមិនធានា

បណ្ណសន្យារ៉ាប់រងនេះ នឹងមិនផ្តល់សំណងចំពោះករណី៖

១. ការបាត់បង់ដោយគ្មានការពន្យល់ ការបាត់បង់ដោយមានអាថ៌កំបាំង ការបាត់បង់ ឬការខ្វះខាតដែលត្រូវបានបង្ហាញក្នុងពេលគិតបញ្ជីសន្និធិ ការខ្វះខាតដោយសារកំហុសឆ្គងគណនេយ្យ ឬកំហុសឆ្គងរដ្ឋបាល ការលុបចោល ឬប្រតិបត្តិការខុស។
២. ការបាត់បង់ ឬខូចខាតដោយសារ ឬតាមរយៈការឃុបឃិត ឬការលួចបន្លំដោយ ឬការបំបាត់មិនសមរម្យដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកណាម្នាក់ ឬអ្នកដែលធ្វើការអោយអ្នកត្រូវបានធានារ៉ាប់រង។
៣. ការបាត់បង់ ឬខូចខាតលើរូបិយវត្ថុដែលដឹកដោយក្រុមហ៊ុនដឹកជញ្ជូនរូបិយវត្ថុ ក្រុមហ៊ុនដឹកជញ្ជូនអាជីព ក្រុមហ៊ុនដឹកជញ្ជូនសាធារណៈ។
៤. ការបាត់បង់ពីយានយន្តដែលត្រូវម្ចាស់ ឬអ្នកបើកបរចតទុកចោលបើទោះបីជាបានចាក់សោរ ឬអត់ក៏ដោយ។
៥. ការបាត់បង់ពីទូរសុវត្ថិភាព ឬឃ្លាំងដែលបានបើកដោយសោរ ឬដោយការប្រើតាមព័ត៌មានលម្អិតពីលេខសម្ងាត់ដែលបានទុកចោលនៅក្នុងបរិវេណរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងអំឡុងពេលបិទអាជីវកម្ម។
៦. ការបាត់បង់ហិរញ្ញវត្ថុ ការបាត់បង់ ឬការខ្វះខាតដោយសារមូលហេតុប្រែប្រួលរូបិយបណ្ណ ឬការធ្លាក់ចុះថ្លៃ។
៧. ការបាត់បង់ ឬខូចខាតទ្រព្យសម្បត្តិដែលកើតឡើងក្នុងអំឡុងពេល ឬក្រោយពេលបាតុកម្ម និងចលាចលសង្គម។
៨. ផលវិបាកនៃសង្គ្រាម ការឈ្លានពាន ឬការវាយប្រហារដោយសត្រូវបរទេស (ទោះសង្គ្រាមនោះបានប្រកាសក្តី ឬមិនបានប្រកាសក្តី) សង្គ្រាមស៊ីវិល ការបះបោរ ការបដិវត្ត ការសមគំនិតក្បត់របស់យោធា ឬការធ្វើរដ្ឋប្រហារ

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ក្នុងការដណ្តើមអំណាច។

៩. គ្រោះថ្នាក់ ការបាត់បង់ ការបំផ្លាញ ការខូចខាតទៅលើទ្រព្យសម្បត្តិ ឬការចំណាយដែលកើតឡើងមកពី ឬផលវិបាកនានា ទោះបីដោយផ្ទាល់ក្តី ឬប្រយោលក្តីដោយសារជាតិវិទ្យុសកម្ម ឬការឆ្លងនៃជាតិវិទ្យុសកម្មពីចំហេះនុយក្លេអ៊ែរ ឬសញ្ញវុធនុយក្លេអ៊ែរ ឬកាកសំណល់នុយក្លេអ៊ែរ ឬការឆេះនៃចំហេះនុយក្លេអ៊ែរ ក្នុងន័យនេះការឆេះនឹងរួមបញ្ចូលទាំងដំណើរការផ្ទុះបរមាណូដោយឯកឯងផងដែរ។

១០. ការបាត់បង់ ឬខូចខាតដែលមានកើតឡើងនៅក្រៅប្រទេស ឬនៅក្រៅទីតាំងធានារ៉ាប់រង ដែលមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រង។

១១. ការវាយប្រហារតាមប្រព័ន្ធអ៊ិនធើណែត (CL380)

ក. យោងតាមចំណុច (ខ) ខាងក្រោម គ្មានករណីណាមួយដែលការធានារ៉ាប់រងនេះត្រូវផ្តល់សំណងលើការបាត់បង់ ការខូចខាត ទំនួលខុសត្រូវ ឬការចំណាយដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដោយសារ ឬចូលរួមដោយ ឬកើតឡើងពីការប្រើ ឬប្រត្តិបត្តិការ ដែលជាមធ្យោបាយធ្វើឱ្យមានផលប៉ះពាល់ចេញពីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ កម្មវិធីសូហ្វវែរកុំព្យូទ័រកូដ ដែលធ្វើឱ្យខូចប្រព័ន្ធ មេរោគកុំព្យូទ័រ ឬដំណើរការ ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀត។

ខ. នៅពេលដែលចំណុចនេះត្រូវបានកែប្រែលើបណ្ណសន្យារ៉ាប់រងដើម្បីធានាលើហានិភ័យសង្ត្រាម សង្ត្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការរើបម្រះ ជម្លោះស៊ីវិល អំពើអរិភាពដោយប្រើអំណាច ឬភេវកម្ម ឬសកម្មភាពរបស់បុគ្គលណាមួយដើម្បីនយោបាយ ចំណុច (ក) មិនត្រូវមិនធានាលើការបាត់បង់ (ដែលនឹងត្រូវធានា) កើតចេញពីការប្រើកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ កម្មវិធីសូហ្វវែរកុំព្យូទ័រ ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀតនៅក្នុងប្រព័ន្ធបើកដំណើរការ និង/ឬប្រព័ន្ធណែនាំ និង/ឬយន្តការនៃការបាញ់អាវុធ ឬមីស៊ីល។

១២. ករណីមិនធានាលើភេរវកម្ម (NMA 2921)

ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដ្ឋិលេខណាមួយ វាត្រូវបានឯកភាពថាការធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាតថ្លៃចំណាយតាមលក្ខណៈណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី កើតឡើងដោយសារកើតចេញពី ឬពាក់ព័ន្ធនឹងអំពើភេរវកម្ម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេងទៀតដែលចូលរួមក្នុងពេលដំណាលគ្នា ឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ។ ក្នុងគោលបំណងនៃបដ្ឋិលេខនេះ អំពើភេរវកម្មសំដៅដល់អំពើ រួមទាំងប៉ុន្តែមិនកំណត់ចំពោះការប្រើកម្លាំង ឬហិង្សា និង/ឬការគំរាមកំហែងពីបុគ្គលណាម្នាក់ ឬក្រុមណាមួយ មិនថាធ្វើតែឯងក្តី ឬក្នុងនាមជាតំណាងក្តី ឬពាក់ព័ន្ធនឹងស្ថាប័ន ឬរដ្ឋាភិបាលក្តី ដែលធ្វើឡើងក្នុងគោលបំណងនយោបាយ សាសនា មនោគម ឬគោលបំណងដែលស្រដៀងនេះ រួមទាំងចេតនាដើម្បីមានឥទ្ធិពលលើរដ្ឋាភិបាល និង/ឬធ្វើឱ្យសាធារណជន ឬផ្នែកណាមួយនៃសាធារណៈមានការភ័យខ្លាច។ បដ្ឋិលេខនេះក៏មិនធានាលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាមលក្ខណៈណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី កើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើធ្វើឡើងក្នុងការគ្រប់គ្រង ការពារ បង្ក្រាប ឬវិធីណាមួយទាក់ទងនឹងអំពើភេរវកម្ម។ ប្រសិនបើក្រុមហ៊ុន

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតីC, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មកភ
ភជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ចោទប្រកាន់ថាដោយហេតុផលនៃបដិ្ឋលេខនេះ ការបាត់បង់ ការខូចខាត ថ្លៃចំណាយមិនត្រូវបានធានាដោយបណ្ណសន្យារ៉ាប់រងនេះទេ នោះក្នុងបន្ទុកនៃការអះអាងផ្ទុយពីនេះត្រូវធ្លាក់លើអ្នកត្រូវបានធានារ៉ាប់រង។ ក្នុងករណីដែលផ្នែកណាមួយនៃបដិ្ឋលេខនេះត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន នោះផ្នែកដែលនៅសល់នៅតែមានសុពលភាព និងមានប្រសិទ្ធភាព។

១៣. ករណីមិនធានាលើហានិភ័យនយោបាយ៖

ទោះបីមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដិ្ឋលេខណាមួយដែលត្រូវបានភ្ជាប់ជាមួយគឺត្រូវបានឯកភាពថា ការធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ខូចខាតថ្លៃចំណាយ ទោះបីតាមលក្ខណៈណាក៏ដោយមិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តីដែលកើតឡើងដោយសារ ឬពាក់ព័ន្ធនឹងករណីដែលបានចែងដូចខាងក្រោមដោយមិនគិតពីបុព្វហេតុ ឬព្រឹត្តិការណ៍ផ្សេងទៀតដែលចូលរួមក្នុងពេលដំណាលគ្នា ឬផ្សេងគ្នាចំពោះការបាត់បង់ឡើយ។ **"ការរឹបអូស ការដកហូត ការធ្វើជាតូបនីយកម្ម ការបញ្ជាពីមេបញ្ជាការ ការឡោមព័ទ្ធ ការបំផ្លាញ ឬការខូចខាតដល់ទ្រព្យសម្បត្តិដោយសារការបញ្ជារបស់រដ្ឋាភិបាល ឬសិទ្ធិអំណាច ឬ សាធារណៈ អាជ្ញាធរក្រុង ឬមូលដ្ឋានដែលទ្រព្យសម្បត្តិនោះស្ថិតនៅក្នុងតំបន់នោះ ការចាប់ ឬ ការបំផ្លាញក្រោមបទបញ្ជាគយ ឬការដាក់អោយនៅដាច់ដោយឡែកពីគេ"** បដិលេខនេះក៏មិនធានាលើការបាត់បង់ ការខូចខាតថ្លៃចំណាយតាមលក្ខណៈណាក៏ដោយមិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តីកើតឡើងដោយសារកើតចេញពី ឬពាក់ព័ន្ធនឹងអំពើធ្វើឡើងក្នុងការគ្រប់គ្រងការពារបង្ក្រាប ឬវិធីណាមួយទាក់ទងនឹងអំពើខាងលើ។

១៤. ការដាក់ទណ្ឌកម្ម ការដាក់កំហិត និង ករណីមិនធានា (LMA3100)

ក្រុមហ៊ុនត្រូវបានសន្មតមិនផ្តល់ការធានា និងមិនធ្វើសំណងដល់ការទាមទារ ឬផ្តល់អត្ថប្រយោជន៍ ប្រសិនបើជាការផ្តល់ការធានានេះ ការធ្វើសំណងនេះ ឬការផ្តល់អត្ថប្រយោជន៍នេះនឹងបណ្តាលឱ្យក្រុមហ៊ុនប្រឈមនឹងការដាក់ទណ្ឌកម្ម ការហាមឃាត់ ការរឹតត្បិតក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬបញ្ញត្តិកម្មរបស់សហភាពអ៊ឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។

១៥. ករណីមិនធានាលើជំងឺឆ្លងរាតត្បាត ឬកូវីដ១៩

ទោះបីជាមានប្រការណាមួយចែងផ្ទុយពីការធានារ៉ាប់រងនេះក៏ដោយ ក៏ការធានារ៉ាប់រងនេះមិនផ្តល់សំណងលើការបាត់បង់ ការខូចខាត ទំនួលខុសត្រូវ ថ្លៃចំណាយប្រាក់ពិន័យ ការផាក ឬចំនួនណាមួយដែលបណ្តាលមកពីជាប់ពាក់ព័ន្ធនឹង ឬទាក់ទងជាមួយ ឬកើតចេញដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីពីករណីណាមួយខាងក្រោម រួមបញ្ចូលទាំងការភ័យខ្លាចណាមួយ ឬទទួលការគំរាមកំហែងពីការឆ្លងនោះ មិនថាឆ្លងពិតមែនក្តី ឬជាការយល់ឃើញក្តី៖

ក. ជំងឺឆ្លងរាតត្បាត មេរោគ បាក់តេរី ឬសារពាង្គកាយផ្សេង ឬបម្រែបម្រួលណាមួយមិនថាវាមាន ឬគ្មានជីវិតក្តី និងមីក្រូសរីរាង្គ (មិនថាមាន ឬគ្មានរោគសញ្ញាក៏ដោយ)

ខ. មេរោគកូរ៉ូណា កូវីដ១៩ រួមទាំងការបំប្លែងខ្លួន ឬបម្រែបម្រួលរូបរាងថ្មីរបស់វា

គ. ជំងឺរាតត្បាតដែលបានប្រកាសដោយអង្គការសុខភាពពិភពលោក ឬ រាជរដ្ឋាភិបាល។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ៧៖ ទីតាំងភូមិសាស្ត្រនៃការធានា

ទីតាំងក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

ផ្នែកទី ៨៖ លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង

នៅក្នុងបណ្ណសន្យាធានារ៉ាប់រងនេះ អ្នកទទួលផល ឬអ្នកទទួលសំណង ត្រូវតែជាភាគីដែលម្ចាស់បណ្ណសន្យារ៉ាប់រងដែលបានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ឬអ្នកទទួលផលស្របតាមច្បាប់របស់ ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង។

ផ្នែកទី ៩៖ ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

រាល់ការកែប្រែ ឬការបន្ថែមលក្ខខណ្ឌណាមួយលើបណ្ណសន្យារ៉ាប់រងដើម គឺតម្រូវឱ្យភាគីទាំងសងខាងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែប្រែ ឬបន្ថែមនេះតាមរយៈប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិច ឬផ្ញើជាលិខិតជូនដំណឹងទៅកាន់ភាគីដែលត្រូវបានស្នើឱ្យមានការកែប្រែ ឬបន្ថែមនេះ។ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីស្នើសុំការកែប្រែ ឬបន្ថែមលក្ខខណ្ឌណាមួយពីម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងហើយនោះ ក្រុមហ៊ុននឹងត្រូវពិនិត្យ និងជូនដំណឹងដល់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងចំពោះការយល់ព្រម ឬបដិសេធការស្នើសុំកែប្រែ ឬបន្ថែមលើបណ្ណសន្យារ៉ាប់រងនោះ ក្នុងរយៈពេលយ៉ាងយូរ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។

រាល់ការកែប្រែ ឬបន្ថែមទាំងអស់នឹងមានសុពលភាព លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំ និង ម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នកត្រូវបានធានារ៉ាប់រង និងមានចែងក្នុងបដ្ឋិលេខ។

ក្នុងករណីមានការខកខានមិនបានជូនដំណឹងអំពីការកែប្រែដូចបានរៀបរាប់ខាងលើ លក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងដើមនឹងត្រូវបានអនុវត្ត ហើយការទាមទារសំណងដែលកើតឡើងដោយសារការកែប្រែនោះ អាចនឹងត្រូវបានបដិសេធ។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍C, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ១០៖ ការបន្តកិច្ចសន្យាធានារ៉ាប់រង

សុពលភាពនៃបណ្ណសន្យារ៉ាប់រង នឹងផុតកំណត់នៅកាលបរិច្ឆេទដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ការស្នើសុំបន្តបណ្ណសន្យារ៉ាប់រង ត្រូវធ្វើឡើងឱ្យបានមុនកាលបរិច្ឆេទផុតសុពលភាព នៃបណ្ណសន្យារ៉ាប់រង។

រយៈពេលនៃការធានារ៉ាប់រងនឹងត្រូវបន្តស្របទៅតាមសេចក្តីណែនាំអំពីការបន្តរយៈពេលធានារ៉ាប់រង ដោយត្រូវបានចុះហត្ថលេខាដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកតំណាងឱ្យអ្នកត្រូវបានធានារ៉ាប់រង ឬភ្នាក់ងារជើងសាធានារ៉ាប់រង និងត្រូវបានប្រគល់ជូនក្រុមហ៊ុន ឬទទួលដោយក្រុមហ៊ុនតាមរយៈលិខិតអនុសិដ្ឋិ អ្នកនាំសំបុត្រ ឬលិខិតប្រគល់ដោយផ្ទាល់ ឬអ៊ីម៉ែល និងការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីខាងក្រុមហ៊ុនដូចគ្នា។

វិសាលភាពនៃការធានា ឬអត្ថប្រយោជន៍នៃការធានានៅក្រោមបណ្ណសន្យារ៉ាប់រង និង/ឬខចែង និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងរួមមានជាអាទិ៍ បុព្វលាភធានារ៉ាប់រងជាកម្មវត្ថុនៃការកែប្រែ។

ផ្នែកទី ១១៖ ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងមានបំណងបញ្ចប់នូវបណ្ណសន្យារ៉ាប់រងនេះ នោះម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុន ក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ មុនពេលដល់កាលបរិច្ឆេទកំណត់នៃការបញ្ចប់បណ្ណសន្យារ៉ាប់រង។ ក្នុងករណីដែលលិខិតស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រងមិនបានភ្ជាប់មកជាមួយនូវឯកសារគ្រប់គ្រាន់ទេ នោះក្រុមហ៊ុននឹងជូនដំណឹងមកកាន់ម្ចាស់បណ្ណ ឬអ្នកត្រូវបានធានារ៉ាប់រងអំពីចំណុចខ្វះខាត ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រង។ ហើយក្រុមហ៊ុននឹងធ្វើការជូនដំណឹង អំពីឆ្លើយតបទៅម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង អំពីការយល់ព្រម ឬបដិសេធដោយមានមូលហេតុត្រឹមត្រូវជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រង និងឯកសារគ្រប់គ្រាន់។ ក្រុមហ៊ុននឹងបង្វិលប្រាក់ ត្រឡប់ទៅវិញក្នុងរយៈពេលយ៉ាងយូរ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃព្រមព្រៀងបញ្ចប់បណ្ណសន្យារ៉ាប់រង ប៉ុន្តែក្រុមហ៊ុនក៏អាចស្នើសុំពេលវេលាបន្ថែមផងដែរក្នុងការបង្វិលប្រាក់ ដោយផ្អែកលើហេតុផលសមស្រប និងមានការឯកភាពពី **ន.ធ.ក**។ ក្នុងករណីនេះផងដែរ ក្រុមហ៊ុននឹងបង្វិលត្រលប់ជូននូវចំនួន ៩០ (កៅសិប) ភាគរយនៃបុព្វលាភដែលនៅសល់។ ចំពោះសំណើនៃការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើមានការទាមទារសំណងណាមួយកើតឡើង ហើយខាងក្រុមហ៊ុនបានបង់នូវសំណងនោះរួចរាល់ នោះក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចក្នុងការបង្វិលសងនូវបុព្វលាភសម្រាប់រយៈពេលដែលនៅសល់នោះទេ។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ១២៖ ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកត្រូវបានធានារ៉ាប់រង ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ក្នុងករណីដូចខាងក្រោម៖

- បុព្វលាភធានារ៉ាប់រងមិនត្រូវបានបង់ក្រោយរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងមានសុពលភាព។
- ក្រុមហ៊ុនរកឃើញថាម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងមានការលាក់បាំងក្លែងបន្លំ និង/ឬ មិនបានបង្ហាញព័ត៌មានពិត។

ផ្នែកទី ១៣៖ ការទាមទារសំណង

ដើម្បីទូទាត់សំណងទៅឱ្យភាគីតតិយជន ឬការចំណាយផ្សេងទៀតដែលទាក់ទងនឹងឧប្បត្តិហេតុ លុះត្រាតែមានការព្រមព្រៀងពីក្រុមហ៊ុនយើងខ្ញុំរបស់យើង។

បណ្ណសន្យារ៉ាប់រងនេះមានលក្ខខណ្ឌ និងនីតិវិធីសម្រាប់ទាមទារសំណងដូចខាងក្រោម៖

ចំណុច ក. លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង

បណ្ណសន្យារ៉ាប់រងនេះតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំទាមទារសំណង ត្រូវតែជាភាគីដែលស្របច្បាប់ដូចមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ឬសាច់ញាតិរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលមានឯកសារផ្លូវច្បាប់បញ្ជាក់ និងទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធ។

ចំណុច ខ. នីតិវិធីនៃការផ្តល់ព័ត៌មាន

ក្នុងករណីមានបញ្ហាកើតឡើងអ្នកត្រូវបានធានារ៉ាប់រងត្រូវតែ៖

១. ជូនដំណឹងមកក្រុមហ៊ុនយើងខ្ញុំភ្លាមៗ

- អ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងមកកាន់ក្រុមហ៊ុនយើងខ្ញុំឱ្យបានឆាប់បំផុត តាមរយៈលេខទូរស័ព្ទបន្ទាន់ឥតគិតថ្លៃ ២៤ (ម្ភៃបួន) ម៉ោង របស់យើងខ្ញុំ ឬភ្នាក់ងារជើងសាធានារ៉ាប់រងសម្រាប់បញ្ហាបាត់បង់ ឬខូចខាតដែលបានកើតមានឡើង និងអាចបង្កជាការទាមទារសំណងក្រោមបណ្ណសន្យារ៉ាប់រង។

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG, KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

- សូមចងចាំថាវាពិតជាមានសារៈសំខាន់ណាស់ ក្នុងការផ្តល់ដំណឹងមកកាន់ក្រុមហ៊ុនយើងខ្ញុំតាមពេលដែលបានកំណត់ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលមានបញ្ហាបាត់បង់ ឬខូចខាតកើតឡើង។
- ក្រុមហ៊ុននឹងឆ្លើយតបទៅកាន់អ្នកត្រូវបានធានារ៉ាប់រង ដើម្បីបញ្ជាក់ពីការទទួលបាននូវការជូនដំណឹងអំពីហានិភ័យដែលកើតឡើងតាមរយៈទូរស័ព្ទ ឬការផ្ញើសារតាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពីទទួលបានការជូនដំណឹង។
- ក្រុមហ៊ុននឹងផ្តល់ពាក្យស្នើសុំទាមទារសំណង តាមទម្រង់របស់ក្រុមហ៊ុន និងព្រមទាំងផ្តល់បញ្ជីឯកសារតម្រូវទៅកាន់អ្នកត្រូវបានធានារ៉ាប់រង ដែលទទួលរងការបាត់បង់ ឬការខូចខាតស្របតាមបណ្ណសន្យារ៉ាប់រង ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពីទទួលបានការជូនដំណឹងអំពីហានិភ័យធានារ៉ាប់រង។
- ក្នុងករណីដែលការស្នើសុំទាមទារសំណងធានារ៉ាប់រង មិនមានឯកសារគ្រប់គ្រាន់ ឬការបំពេញពាក្យស្នើសុំទាមទារសំណងមិនបានត្រឹមត្រូវ ក្រុមហ៊ុននឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមរយៈសារអេឡិចត្រូនិក ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីចំណុចខ្វះខាត ដល់អ្នកទាមទារសំណងក្នុងរយៈពេលយ៉ាងយូរ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានការស្នើសុំទាមទារសំណង។

២. ការផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ

- អ្នកត្រូវបានធានារ៉ាប់រង គួរតែផ្តល់ឱ្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនយើងខ្ញុំដូចខាងក្រោម៖
- ហេតុការណ៍នៃការបាត់បង់ ឬការខូចខាត
- ដើមហេតុ ឬកំរិតនៃការបាត់បង់ ឬការខូចខាតទៅលើទ្រព្យសម្បត្តិ។

៣. ការកាត់បន្ថយនៃការបាត់បង់តាមលទ្ធភាពដែលធ្វើទៅបាន

- វាពិតជាមានសារៈសំខាន់ដែលអ្នកត្រូវបានធានារ៉ាប់រងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់បន្ថយការខាតបង់ផ្សេងៗទៀត។
- អ្នកត្រូវបានធានារ៉ាប់រងអាចចូលរួមចំណែកតាមលទ្ធភាពរបស់គាត់ ដើម្បីកាត់បន្ថយកំរិតនៃការបាត់បង់ ឬខូចខាត។

៤. ការផ្តល់ដំណឹងដល់អាជ្ញាធរប៉ូលីស

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

- ក្នុងករណីដែលមានការបាត់បង់ ឬខូចខាតបណ្តាលមកពីការលួច ឬប្លន់នោះអ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ដំណឹងដល់អាជ្ញាធរប៉ូលីសអំពីការបាត់បង់នោះឱ្យបានឆាប់ជាទីបំផុត។

៥. មិនត្រូវទទួលយកការទទួលខុសត្រូវណាមួយ

- អ្នកត្រូវបានធានារ៉ាប់រងមិនត្រូវទទួលខុសត្រូវ ចចារ ឬធ្វើការទទួលយក ការផ្តល់ការសន្យា ឬផ្តល់ជាសំណងណាមួយដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុ ឬការទាមទារសំណង ដោយគ្មានការយល់ព្រមពីក្រុមហ៊ុនយើងខ្ញុំឡើយ។

៦. ការរក្សាទុកផ្នែក ឬទ្រព្យសម្បត្តិដែលទទួលរងការខូចខាត៖

- ក្នុងហេតុការណ៍ដែលកើតមានឡើង ក្រុមហ៊ុនយើងខ្ញុំនឹងបញ្ជូនអ្នកតំណាង ឬភ្នាក់ងារវាយតម្លៃហានិភ័យដើម្បីត្រួតពិនិត្យពីស្ថានភាព។ អ្នកត្រូវបានធានារ៉ាប់រង ត្រូវធានាឱ្យបានថាផ្នែក ឬទ្រព្យសម្បត្តិដែលទទួលរងការខូចខាតត្រូវបានរក្សាទុក និងអាចឱ្យខាងក្រុមហ៊ុនយើងខ្ញុំអាចត្រួតពិនិត្យបាន។
- ក្នុងករណីណាក៏ដោយ អ្នកត្រូវបានធានារ៉ាប់រងមិនមានសិទ្ធិក្នុងការបោះបង់ទ្រព្យសម្បត្តិណាមួយមកឱ្យក្រុមហ៊ុនយើងខ្ញុំនោះទេ ទោះបីជាទ្រព្យសម្បត្តិនោះត្រូវបានកាន់កាប់ដោយក្រុមហ៊ុនយើងខ្ញុំ ឬអត់ក៏ដោយ។

ចំណុច គ. ការផ្តល់ឯកសារ ឬកស្តុតាងក្នុងការទាមទារសំណង

នៅពេលមានការទាមទារសំណងកើតឡើង អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ឯកសារមកកាន់យើងខ្ញុំដូចខាងក្រោម៖

- អ្នកត្រូវបានធានារ៉ាប់រង ត្រូវបំពេញទម្រង់ទាមទារសំណងឱ្យបានត្រឹមត្រូវ និងបញ្ជូនមកកាន់ក្រុមហ៊ុនយើងខ្ញុំ។ ទម្រង់ទាមទារសំណងនេះ ត្រូវបំពេញព័ត៌មានដែលចាំបាច់ ហើយ ព័ត៌មានចាំបាច់ដែលបានបំពេញនោះ ត្រូវតែជាការពិត។
- អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនរបស់អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកតំណាងស្របច្បាប់របស់អ្នកដែលត្រូវបានធានារ៉ាប់រង។
- វឌ្ឍនភាពនៃសំណង់អំឡុងពេលដែលមានការបាត់បង់ ឬ ខូចខាត។
- កស្តុតាងនៃការបាត់បង់ ឬខូចខាតលើកិច្ចសន្យាសាងសង់ គម្រោងសាងសង់ និង បរិក្ខារ ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ភាគីតតិយជន (ប្រសិនបើមាន)។
- ទម្រង់វាយតម្លៃនៃការជួសជុល សម្រាប់ការបាត់បង់ ឬខូចខាតលើកិច្ចសន្យាសាងសង់ គម្រោងសាងសង់ និងបរិក្ខារទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់ភាគីតតិយជន(ប្រសិនបើមាន)។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG, KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

- វិក្កយបត្រច្បាប់ដើមណាដែលពាក់ព័ន្ធនឹងការជួសជុលលើវត្ថុដែលខូចខាត ឬការខូចខាតទៅលើទ្រព្យសម្បត្តិដែលនៅជុំវិញ (ប្រសិនបើមាន)។
- ឯកសារចាំបាច់ទាំងអស់ ត្រូវបញ្ជូនមកដោយភ្ជាប់ជាមួយក្នុងការទាមទារសំណង ដើម្បីផ្ទៀងផ្ទាត់លើការបាត់បង់ផ្នែកហិរញ្ញវត្ថុ ដែលបណ្តាលមកពីការបាត់បង់ ឬខូចខាតនោះ។
- ឯកសារពាក់ព័ន្ធផ្សេងៗ ប្រសិនបើមានការចាំបាច់។

កំណត់ចំណាំ៖ ភ្នាក់ងារវាយតម្លៃហានិភ័យ នឹងត្រូវបានចាត់តាំងប្រសិនបើទំហំនៃការទាមទារសំណងនោះមានទំហំ (ធំជាង ឬស្មើ ២៥ ០០០ដុល្លារអាមេរិក) ឬករណីទាមទារមានភាពស៊ាំញាំ។ របាយការណ៍របស់ភ្នាក់ងារវាយតម្លៃហានិភ័យមានសារៈសំខាន់ណាស់ក្នុងការសម្រេចការទូទាត់សំណង។ ថ្លៃឈ្នួល នៃភ្នាក់ងារវាយតម្លៃហានិភ័យ នឹងត្រូវបានបង់ដោយក្រុមហ៊ុនយើងខ្ញុំ ក្នុងករណីដែល ក្រុមហ៊ុនយើងខ្ញុំជាអ្នកចាត់តាំង។

ចំណុច ឃ. រយៈពេលអតិបរមានៃការដោះស្រាយការទូទាត់សំណងជូនអតិថិជន៖

រាល់ឯកសារសំខាន់ក៏ដូចជាព័ត៌មាន និងកស្តុតាងតម្រូវត្រូវតែផ្តល់ឱ្យនាយកដ្ឋានដោះស្រាយសំណងជាចាំបាច់ឱ្យបានឆាប់រហ័សបន្ទាប់ពីគ្រោះថ្នាក់ ឬការខូចខាតបានកើតឡើង។

ក្រុមហ៊ុន នឹងធ្វើការឆ្លើយតបទៅកាន់អ្នកទាមទារសំណង អំពីការបដិសេធ ឬការសម្រេចផ្តល់សំណងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនបានទទួលការស្នើសុំទាមទារសំណង និងឯកសារតម្រូវគ្រប់គ្រាន់។

ក្រុមហ៊ុន អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក នឹងធ្វើការទូទាត់សំណងជូនអ្នកដាក់ពាក្យស្នើសុំទាមទារសំណងតាមកាលកំណត់ដូចខាងក្រោម៖

- ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកដាក់ពាក្យស្នើសុំទាមទារសំណងបានឯកភាពយកសំណងធានារ៉ាប់រង ចំពោះការទូទាត់សំណងទាំងស្រុង ឬ
- ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទទួលយកសំណងធានារ៉ាប់រងរវាងក្រុមហ៊ុន អង្គរ ជេនេរ៉ាល អ៊ិនសួរេន និងអ្នកដាក់ពាក្យស្នើសុំទាមទារសំណង ចំពោះការទូទាត់សំណងធានារ៉ាប់រងជាដំណាក់កាល។

ការធ្វើសំណងនឹងត្រូវទូទាត់តាមរយៈ មូលប្បទានបត្រ និង/ឬ ផ្ទេរពីគណនីធនាគាររបស់ក្រុមហ៊ុន **អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក**។

ផ្នែកទី ១៤៖ ការរក្សាព័ត៌មានសម្ងាត់

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាបានជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឱ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែត្រូវបានតម្រូវ ឬអនុញ្ញាតដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

ផ្នែកទី ១៥: នីតិវិធីនៃការផ្សះផ្សាវិវាទ

ចំពោះគ្រប់វិវាទនៃបណ្តាសន្យាប៉ាប់រងនេះ ដែលពាក់ព័ន្ធនឹងអាជីវកម្មធានាប៉ាប់រងភាគីណាមួយ ភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានាប៉ាប់រងកម្ពុជា ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទ មុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ។

ផ្នែកទី ១៦: ច្បាប់ និងយុត្តាធិការ

បណ្តាសន្យាប៉ាប់រងនេះ ត្រូវស្ថិតក្រោម និងបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដែនយុត្តាធិការ គឺស្របតាមច្បាប់តុលាការនៃព្រះរាជាណាចក្រកម្ពុជា។

ផ្នែកទី ១៧: លក្ខខណ្ឌទូទៅ

១. ការជូនដំណឹង

រាល់ការជូនដំណឹង ឬការទាក់ទងគ្នាក្រោមបណ្តាសន្យាប៉ាប់រងនេះ នឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនតាមរយៈសារអេឡិចត្រូនិក ឬតាមរយៈប្រៃសណីយ៍មកកាន់អាសយដ្ឋានចុងក្រោយ របស់ក្រុមហ៊ុនដែលមានចែងក្នុងតារាងសង្ខេបបណ្តាសន្យាប៉ាប់រង ឬវិញ្ញាបនបត្រធានាប៉ាប់រង។

២. វិធានការប្រុងប្រយ័ត្ន

អ្នកត្រូវបានធានាប៉ាប់រងក្រោមការចំណាយផ្ទាល់ខ្លួនត្រូវមានការប្រុងប្រយ័ត្នដែលសមហេតុផល និងអនុវត្តតាមរាល់ការណែនាំពីក្រុមហ៊ុន ដើម្បីបង្ការនូវការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវ និងត្រូវគោរពតាមការតម្រូវនៃច្បាប់ និងការណែនាំរបស់រោងចក្រ ឬអ្នកផលិត។

៣. ការផ្តល់ព័ត៌មានខុស

ប្រសិនបើមានការផ្តល់ព័ត៌មានខុសពីការពិតអំពីប្រភេទអាជីវកម្ម ឬបរិវេណដែលត្រូវបានធានាប៉ាប់រង ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការធានាប៉ាប់រង ឬការបកស្រាយខុសការពិតដែលត្រូវបានប្រើប្រាស់

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

សម្រាប់ការព្យាករណ៍ហានិភ័យ ឬការខកខានក្នុងការផ្តល់ព័ត៌មានពិតប្រាកដ ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះបណ្ណសន្យារ៉ាប់រងនោះទេ។

៤. ការប្រែប្រួលនៃហានិភ័យធានារ៉ាប់រង

ក. អ្នកតំណាងរបស់ក្រុមហ៊ុន នឹងមានសិទ្ធិនៅក្នុងពេលវេលាសមស្របណាមួយ ដើម្បីត្រួតពិនិត្យមើលពីហានិភ័យ ហើយអ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ឱ្យអ្នកតំណាងរបស់ក្រុមហ៊ុននូវគ្រប់ព័ត៌មានលម្អិតចាំបាច់សំរាប់ការវាយតម្លៃទៅលើហានិភ័យ។

ខ. អ្នកត្រូវបានធានារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមៗ មកកាន់ក្រុមហ៊ុនអំពីការប្រែប្រួលនៃហានិភ័យ និងមូលហេតុក្រោមការចំណាយផ្ទាល់ខ្លួន ការប្រុងប្រយ័ត្នបន្ថែម នឹងត្រូវចាត់ចែងទៅតាមស្ថានភាពជាក់ស្តែង និងវិសាលភាពនៃការធានារ៉ាប់រង និង/ឬបុព្វលាភធានារ៉ាប់រងនឹងអាចត្រូវបានកែសម្រួលប្រសិនបើចាំបាច់។ គ្មានការកែប្រែណាមួយត្រូវបានធ្វើឡើង ឬអនុញ្ញាតដោយអ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលហានិភ័យមានការកើនឡើង លើកលែងតែការបន្តនៃការធានារ៉ាប់រងត្រូវបានយល់ព្រមជាលាយលក្ខណ៍អក្សរដោយក្រុមហ៊ុន។

៥. សិទ្ធិជំនួសស្តីពីការប្តឹងទាមទារសំណងធានារ៉ាប់រង

អ្នកត្រូវបានធានារ៉ាប់រង ក្រោមការចំណាយរបស់ក្រុមហ៊ុនត្រូវធ្វើ និងអនុញ្ញាតឱ្យធ្វើនូវគ្រប់អំពើដែលចាំបាច់ ឬតម្រូវដោយក្រុមហ៊ុនដើម្បីជាផលប្រយោជន៍នៃសិទ្ធិ ឬការដោះស្រាយ ឬដើម្បីទទួលបានការជួយឧបត្ថម្ភការទូទាតសំណងពីភាគី (ក្រៅពីអ្នកត្រូវបានធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ) ដែលក្រុមហ៊ុនមានសិទ្ធិ ឬសិទ្ធិជំនួសក្នុងការទាមទារឱ្យបង់ប្រាក់ ឬធ្វើឱ្យល្អឡើងវិញចំពោះការបាត់បង់ ឬការខូចខាតក្រោមបណ្ណសន្យារ៉ាប់រងនេះ ទោះបីជាអំពើនេះអាចក្លាយជាការចាំបាច់ ឬតម្រូវមុនពេល ឬក្រោយពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលបានការទូទាត់សំណងពីក្រុមហ៊ុន។

៦. ការក្លែងបន្លំ

ប្រសិនបើការទាមទារសំណងមានការក្លែងបន្លំ ឬប្រសិនបើមានការប្រកាសក្លែងក្លាយត្រូវបានធ្វើឡើង ឬប្រើក្នុងការទាមទារសំណង ឬប្រសិនបើមធ្យោបាយក្លែងបន្លំណាមួយត្រូវបានប្រើដោយអ្នកត្រូវបានធានារ៉ាប់រង ឬសកម្មភាពណាមួយក្នុងនាមអ្នកត្រូវបានធានារ៉ាប់រងក្នុងគោលបំណងដើម្បីទទួលបានផលប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ ឬប្រសិនបើការទាមទារសំណងត្រូវបានធ្វើឡើង និងត្រូវបានបដិសេធហើយគ្មានពាក្យបណ្តឹងណាមួយត្រូវបានធ្វើឡើងក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីថ្ងៃបដិសេធ ឬប្រសិនបើមានការប្តឹងទៅកាន់អាជ្ញាកណ្តាល ដោយផ្អែកទៅតាមលក្ខខណ្ឌនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីថ្ងៃដែលអាជ្ញាកណ្តាលបានចេញសេចក្តីសម្រេច រាល់ផលប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបាត់បង់។

៧. ការធានារ៉ាប់រងផ្សេងៗទៀត

ប្រសិនបើនៅពេលមានការទាមទារសំណងកើតឡើងក្រោមបណ្ណសន្យារ៉ាប់រងនេះ ដែលនាំឱ្យមានការធានា

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

រ៉ាប់រងផ្សេងទៀត ជានារ៉ាប់រងលើការបាត់បង់ ឬការខូចខាត ឬការទទួលខុសត្រូវដូចគ្នា ក្រុមហ៊ុននឹងមិនទទួលខុសត្រូវ ឬចូលរួមធ្វើសំណងលើសពីចំណែកសមាមាត្រនៃការទាមទារសំណងចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវនោះទេ។

ផ្នែកទី ១៨៖ នីតិវិធីប្តឹងតវ៉ា

អនុវត្តចំពោះគ្រប់ចំណុចជានាទាំងអស់

ក្រុមហ៊ុនប្តេជ្ញាក្នុងការផ្តល់សេវាកម្មដ៏ប្រសើរបំផុត ប្រសិនបើអតិថិជនមានការមិនពេញចិត្ត ក្រុមហ៊ុននឹងខិតខំស្វែងរកដំណោះស្រាយភ្លាម ប៉ុន្តែប្រសិនបើក្រុមហ៊ុនមិនអាចដោះស្រាយបញ្ហាបាន ក្រុមហ៊ុននឹងជូនដំណឹងទៅអតិថិជនក្នុងអំឡុងពេល ៤៨ (សែសិបប្រាំបី) ម៉ោង ហើយនឹងខិតខំប្រឹងប្រែងរកដំណោះស្រាយឱ្យអតិថិជនក្នុងអំឡុងពេល ៤ (បួន) សប្តាហ៍ ប្រសិនបើក្រុមហ៊ុននៅតែមិនអាចផ្តល់ដំណោះស្រាយជូនអតិថិជន ក្រុមហ៊ុននឹងជូនដំណឹងដល់អតិថិជននូវរយៈពេលជាក់លាក់មួយដែលក្រុមហ៊ុនអាចរកដំណោះស្រាយជូនអតិថិជនបាន។

ប្រសិនបើអតិថិជនត្រូវការប្តឹងតវ៉ាមិនពេញចិត្ត សូមធ្វើការទំនាក់ទំនងតាមរយៈ៖

ក្រុមការងារបម្រើសេវាកម្មអតិថិជនរបស់ក្រមហ៊ុន៖

ការិយាល័យកណ្តាល

អង្គរ ជេនេរ៉ល អ៊ិនសួរេន ម.ក

អគារលេខដីឡូត៍ C ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ខណ្ឌ ៧មករា

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ៖ (+855) 78 242 424

អ៊ីម៉ែល៖ customerservice@agi.com.kh

ប្រសិនបើក្រុមហ៊ុនមិនអាចរកដំណោះស្រាយលើបណ្តឹងតវ៉ា ក្នុងរយៈពេល ១២ (ដប់ពីរ) សប្តាហ៍ អ្នកត្រូវបានជានារ៉ាប់រងអាចបន្តប្តឹងទៅ៖

និយ័តករធានារ៉ាប់រងកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវ៥៩៨,សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ផ្នែកទី ១៩៖ ព័ត៌មានទំនាក់ទំនង

សូមទំនាក់ទំនងក្រុមហ៊ុនតាមរយៈ៖

អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក

អគារលេខដីឡូតិ៍ C ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នាយកដ្ឋានបម្រើសេវាកម្មអតិថិជន

ទូរស័ព្ទលេខ៖(+855)78 242 424
អ៊ីម៉ែល៖ customerservice@agi.com.kh

នាយកដ្ឋានដោះស្រាយសំណង (២៤/៧)

ទូរស័ព្ទលេខ៖1800 20 24 24
អ៊ីម៉ែល៖ claims@agi.com.kh